ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

# សារជូនពរ

ផ្ញើជូន

នាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ
ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី ៦៥ ទិវាកំណើតកងយោធពលខេមរភូមិន្ទ
ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ - ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៨

**ឯកឧត្តម លោកជំទាវ មេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និង ពលទាហាន គ្រប់ស្ថាប័ន កងឯកភាព នៃកងយោធពលខេមរភូមិន្ទទាំងអស់ ជាទីស្នេហា !**

ក្នុងឱកាសប្រកបដោយមហានក្ខត្តឫក្សដ៏ឧត្តុង្គឧត្តម នៃពិធីរំលឹកខួបអនុស្សាវរីយ៍លើកទី**៦៥** ទិវាកំណើត កងយោធពលខេមរភូមិន្ទ និងស្របជាមួយទិវាបុណ្យឯករាជ្យជាតិ **ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ - ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៨** នេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ កងយោធពលខេមរភូមិន្ទ ក្នុងនាមខ្ញុំផ្ទាល់ សូមផ្ញើជូននូវការសាកសួរសុខទុក្ខ ដោយក្តីនឹករលឹកនិងក្តីស្រឡាញ់រាប់អានដោយមនោសញ្ចេតនាសោមនស្សរីករាយយ៉ាងជ្រាលជ្រៅ និងសូមជូននូវសព្ទសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរគ្រប់យ៉ាងជូនដល់មេបញ្ជាការ មេបញ្ជាការរងគ្រប់លំដាប់ថ្នាក់ នាយទាហាន នាយទាហានរង និង ពលទាហានទាំងអស់ ក្នុងកងយោធពលខេមរភូមិន្ទ ដែលកំពុងបំពេញភារកិច្ចនៅតាមស្ថាប័ន កងឯកភាព នានា ក៏ដូចជាសិក្ខាកាមដែលកំពុងសិក្សាជំនាញផ្សេងៗ នៅតាមបណ្តាប្រទេសជាមិត្ត រួមទាំងកងកម្លាំង បំពេញបេសកកម្មរក្សាសន្តិភាព របស់អង្គការសហប្រជាជាតិ សូមទទួលបានជោគជ័យថ្មីៗបន្តទៀត ជូន ជាតិមាតុភូមិ។

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរយ៉ាងស្មោះចំពោះជោគជ័យ ដ៏ត្រចះត្រចង់និងសមិទ្ធផលដ៏ធំធេង ដែលកងយោធពលខេមរភូមិន្ទយើងសម្រេចបានក្នុងឆ្នាំកន្លងមក ក្នុង នោះការកែទម្រង់កងយោធពលខេមរភូមិន្ទ គឺជាកិច្ចការចាំបាច់ដើម្បីលើកកម្ពស់ពង្រឹងពង្រីកសមត្ថភាពរបស់ កងទ័ព ក្នុងការបំពេញភារកិច្ចការពារអធិបតេយ្យ បូរណភាពដែនដី ការពារព្រះមហាក្សត្រ ការពាររដ្ឋធម្មនុញ្ញ ការពាររាជរដ្ឋាភិបាលស្របច្បាប់មួយកើតឡើងដោយការបោះឆ្នោត រួមចំណែករក្សាការពារសន្តិសុខ សណ្តាប់ ធ្នាប់សង្គម ស្ថិរភាពនយោបាយ នាំមកនូវភាពសុខក្សេមក្សាន្តជូនប្រជាពលរដ្ឋ ។

ទន្ទឹមនិងភារកិច្ចស្នូល កងយោធពលខេមរភូមិន្ទ ក៏បានចូលរួមចំណែកយ៉ាងសកម្មក្នុងការអនុវត្តកម្មវិធី នយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភាជាតិ ដែលបានដាក់ចេញ និងផែនការកែទម្រង់៥

ឆ្នាំរបស់កងយោធពលខេមរភូមិន្ទ សំដៅកសាងឱ្យបានរឹងមាំ មានសមត្ថភាព និងប្រសិទ្ធភាពការងារ ក្នុងការបំពេញតួនាទីភារកិច្ច ការពារជាតិមាតុភូមិ។ យើងបានប្ដេជ្ញាចិត្តយ៉ាងរឹងមាំមោះមុត ក្នុងការការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី និងសន្តិភាពរបស់ប្រទេសជាតិ ជាមួយនេះដែរក៏បានចូលរួមចំណែកយ៉ាងសកម្មក្នុងកិច្ចការពារសន្តិសុខ សណ្ដាប់ធ្នាប់សង្គម ទប់ស្កាត់និងបង្ក្រាបបានទាន់ពេលវេលានូវរាល់បទឧក្រិដ្ឋ បទល្មើសផ្សេងៗ ព្រមទាំងបានរួមចំណែកក្នុងការងារមនុស្សធម៌ ដោយបរិច្ចាគធនធាន សម្ភារៈថវិកា ជាច្រើន តាមរយៈកាកបាទក្រហមកម្ពុជា ដើម្បីជួយសង្គ្រោះប្រជាជនដែលរងគ្រោះ ដោយគ្រោះមហន្តរាយនានា ដែលកើតមានឡើងជាយថាហេតុ។

ក្រៅពីនេះទៀត កងយោធពលខេមរភូមិន្ទ ក៏បានចូលរួមអនុវត្តប្រកបដោយជោគជ័យនូវភារកិច្ចអន្តរជាតិលើវិស័យមនុស្សធម៌ បំពេញបេសកកម្មជាកងកម្លាំងរក្សាសន្តិភាព ក្រោមឆត្ររបស់អង្គការសហប្រជាជាតិដូចជា " **នៅតំបន់អាហ្វ្រិក អឺរុប និងមជ្ឈិមបូព៌ា** " ដើម្បីបុព្វហេតុសន្តិភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិល្អ ដែលជាក្ដីមោទនភាពនិងជាកិត្តិយសដ៏ឧត្តុង្គឧត្តមរបស់កងយោធពលខេមរភូមិន្ទ ក៏ដូចជាប្រជាជាតិកម្ពុជាយើងទាំងមូលដែលមិនធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រពីមុនមក ហើយកម្លាំងទាំងនេះ គឺជាកុលបុត្រដ៏ឆ្នើមដែលធ្វើឱ្យកិត្យានុភាពរបស់ព្រះរាជាណាចក្រកម្ពុជាកាន់តែល្បីរន្ទឺនៅលើឆាកអន្តរជាតិ។

សរុបមកវិញរាល់សមិទ្ធផលដ៏ធំធេងដែលសម្រេចបានកន្លងមកនេះ គឺអាស្រ័យដោយការតស៊ូលះបង់ខិតខំប្រឹងប្រែងពុំខ្លាចនឿយហត់ និងការធ្វើពលិកម្មគ្រប់បែបយ៉ាងរបស់ ឯកឧត្តម លោកជំទាវ មេបញ្ជាការ មេបញ្ជាការរង ក៏ដូចជានាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ ក្នុងកងយោធពលខេមរភូមិន្ទ ក្រោមការដឹកនាំដ៏ត្រឹមត្រូវប្រកបដោយគតិបណ្ឌិតនិងប៉ិនប្រសប់របស់ សម្ដេចអគ្គមហាសេនាបតីតេជោ នាយឧត្តមសេនីយ៍ផុតលេខ ផ្កាយមាស៥ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា គួបផ្សំជាមួយនិងស្មារតីទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំគ្រប់ស្ថាប័ន កងឯកភាព ក្នុងការចាត់តាំងអនុវត្តការងារជាក់ស្ដែង។

**ឯកឧត្តម លោកជំទាវ មេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហាន គ្រប់ស្ថាប័ន កងឯកភាព នៃកងយោធពលខេមរភូមិន្ទទាំងអស់ ជាទីស្នេហា** !

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមថ្លៃថ្លា នៃទិវារំលឹកខួបអនុស្សាវរីយ៍លើកទី**៦៥** ថ្ងៃកំណើតកងយោធពលខេមរភូមិន្ទ និងព្រមជាមួយទិវាបុណ្យឯករាជ្យជាតិ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ កងយោធពលខេមរភូមិន្ទ ក្នុងនាមខ្ញុំផ្ទាល់ សូមផ្ញើជូននូវការសួរសុខទុក្ខប្រកបដោយមនោសញ្ចេតនា ស្រឡាញ់រាប់អានយ៉ាងជ្រាលជ្រៅបំផុតចំពោះ ឯកឧត្តម លោកជំទាវ មេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពល-ទាហាន នៃកងយោធពលខេមរភូមិន្ទទាំងអស់ ដែលកំពុងបំពេញភារកិច្ចនៅតាមស្ថាប័ន កងឯកភាព នៅតាមខ្សែបន្ទាត់តំបន់ព្រំដែន និងកំពុងបំពេញបេសកកម្មអន្តរជាតិ ព្រមទាំងសិក្ខាកាមដែលកំពុងបំពេញការសិក្សាជំនាញផ្សេងៗនៅបណ្ដាប្រទេសជាមិត្ត សូមប្រកបដោយសុខភាពល្អបរិបូរណ៍ កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ អាយុយឺនយូរ ស្មារតីមោះមុត អង់អាចក្លាហាន សម្រេចបានជោគជ័យក្នុងភារកិច្ច ទទួលបានកិត្តិយស កេរ្តិ៍-ឈ្មោះបន្ថែមទៀត ជូនជាតិមាតុភូមិ និងប្រជាជនយើង។

ខ្ញុំសូមសម្ដែងនូវការគោរពដឹងគុណជាអនេកកប្បការចំពោះលោក**ឪពុក អ្នកម្ដាយ បងប្អូន** ជនរួមជាតិទាំងអស់ ដែលបានលះបង់ **កូនចៅ ប្ដីសី បងប្អូន**សាច់ញាតិជាទីស្រឡាញ់របស់ខ្លួន ឲ្យចូលបម្រើក្នុងជួរកងយោធពលខេមរភូមិន្ទ ដើម្បីបុព្វហេតុការពារជាតិមាតុភូមិ និងភាពសុខសាន្តរបស់ប្រជាពលរដ្ឋ។

សូមផ្ញើជូននូវការសួរសុខទុក្ខ ដល់យោធិន **ជំងឺ របួស ពិការ** ដែលកំពុងសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យនានា សូមឲ្យបានឆាប់ជាសះស្បើយពីជំងឺ មានសុខភាពល្អបរិបូរណ៍ និងប្រកបដោយសេចក្ដីសុខចម្រុងចម្រើនគ្រប់ពេលវេលា និងសូមជូនពរដល់អតីតយុទ្ធជន ព្រមទាំងក្រុមគ្រួសារដែលកំពុងរស់នៅក្នុងសង្គមស៊ីវិល សូមមានជីវភាពរស់នៅធូរធានិងប្រកបដោយសុភមង្គលរុងរឿង។

ជាថ្មីម្ដងទៀត សូមជូនពរ **ឯកឧត្ដម លោកជំទាវ មេបញ្ជាការ មេបញ្ជាការរង គ្រប់ស្ថាប័ន គឯឯកភាព នាយទាហាន នាយទាហានរង និងពលទាហាន** ទាំងអស់ ក្នុងកងយោធពលខេមរភូមិន្ទ ព្រមទាំងក្រុមគ្រួសារ សូមទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** ជានិច្ចនិរន្តរ៍តរៀងទៅ។

ថ្ងៃពុធ ១កើត ខែ អស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៨
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្ដេចពិជ័យសេនា **ទៀ បាញ់**